អង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា

*Kampuchean Action for Primary Education*

# សួនកុមារសម្រាប់កុមារពិការ

កំពង់ចាម , ខែ កក្កដា ២០០៥

ឧបត្ថម្ភគាំទ្រដោយអង្គការ យូនីសេហ្វ / ស៊ីដា

# សួនកុមារសម្រាប់កុមារពិការ

## ១. សេចក្តីផ្តើម

- មេរៀននេះគឺផ្តោតជាសំខាន់ទៅលើស្ថានភាពសួនកុមារដែលសិស្សគ្រប់ប្រភេទអាចលេងបាន ។ម្យ៉ាងទៀត មេរៀននេះអាចជួយគ្រូ និងនាយកសាលាលើបញ្ហាដែលធានាថា ទីធ្លាគឺអាចឱ្យសិស្សគ្រប់ប្រភេទ ប្រើប្រាស់បាន ជាពិសេសចំពោះសិស្សពិការ ។ មេរៀននេះមិនបានរៀបរាប់អំពីឧបករណ៍ពិសេសៗដែលត្រូវការសម្រាប់សិស្សពិការ ពីព្រោះគេខ្លាចថាសាលាផ្សេងទៀតមានសិស្សពិការច្រើនដែលជាហេតុធ្វើមានតំរូវការកាន់ច្រើនឡើងៗ ដូចជាបញ្ហាឧបករណ៍ និងបញ្ហាថវិកាជាដើម ។ ដូច្នេះមេរៀននេះ គឺផ្តោតលើការរៀបចំឱ្យបានងាយស្រួល និងបង្កនូវភាពសប្បាយរីករាយដល់សិស្សក្នុងការរៀននៅក្នុងសាលារៀន រួមទាំងសិស្សពិការ ។ មេរៀននេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងមេរៀនរបស់កម្មវិធីសាលាកុមារមេត្រីពីរទៀត ។

*ទីធ្លាសាលាផ្តល់ផាសុខភាព*:មេរៀននេះរៀបរាប់អំពីប្រភេទខុសគ្នានៃឧបករណ៍ដែលអាចដាក់នៅក្នុងសួនកុមារ ។ *សកម្មភាពកុមារជួយកុមារ* : មេរៀននេះបង្ហាញពីរបៀបដែលកុមារអាចជួយគ្នាទៅវិញទៅមកបាន ។ នេះគឺជាទស្សនៈមួយដ៏សំខាន់ក្នុងលើស្ទួយគុណភាពនៃសួនកុមារ ។ សកម្មភាពកុមារជួយកុមារនេះ គឺផ្តោតទៅលើការបង្កើតទំនាក់ទំនងក្នុងសង្គមរវាងកុមារពីរនាក់ ដែលម្នាក់មានអារម្មណ៍ថា ជាអ្នកទទួលខុសត្រូវ និងម្នាក់ទៀតមានអារម្មណ៍ថាត្រូវបានគេឱ្យតំលៃ និងជួយដល់ខ្លួន ។ ទង្វើបែបនេះអាចលើកតំកើននូវការគោរពខ្លួនឯង និងលើកស្ទួយនូវទំនុកចិត្តរបស់បុគ្គលក ។ ទស្សនៈនៃសកម្មភាពកុមារជួយកុមារមានសារៈសំខាន់ណាស់ដើម្បីជួយកុមារពិការ ជាពិសេសគឺនៅក្នុងសួនកុមារដែលជាញឹកញាប់សិស្សមិនមកចូលរួម ។

## ២. វត្ថុបំណង

- សិស្សពិការ (និងសិស្សដែលគ្មានឱកាសផ្សេងទៀត) ត្រូវបានលើកទឹកចិត្តឱ្យចូលរៀនជាទៀងទាត់ ដោយមានការរៀបចំសួនកុមារ ឱ្យសមស្របទៅតាមស្ថានភាពពិការ និងស្ថានភាពជាក់ស្តែងរបស់ពួកគេ ។

## ៣. រយៈពេលៈ

- ២ ទៅ ៣ ម៉ោង

## ៤. សម្ភារ

- ក្រដាសផ្ទាំងធំ
- ហ្វឺតសរសេរ
- ឧបសម្ព័ន្ធ ' ក ' : ករណីសិក្សាស្តីអំពីសួនកុមារពីរដែលមានលក្ខណៈខុសគ្នា ( ឯកសារចែកជូនសម្រាប់សិក្ខាកាមម្នាក់ ១ច្បាប់)
- ឧបសម្ព័ន្ធ ' ខ ' : ការវាយតំលៃលើភាពសមស្របដែលមានកល្ខណៈសម្រាប់ទាំងអស់គ្នានៃសួនកុមារ ( ឯកសារចែកជូនសម្រាប់ សិក្ខាកាមម្នាក់ ១ច្បាប់)

## ៥. លំនាំនៃការបង្រៀន

### ១. ករណីសិក្សាស្តីអំពីសួនកុមារពីរដែលមានលក្ខណៈខុសគ្នា

- ដោយយោងតាមការណែនាំខ្លីៗនៃវត្ថុបំណងរបស់មេរៀននេះ អ្នកសម្របសម្រួលត្រូវចែកឧបសម្ព័ន្ធ ' ក ' ហើយសុំឱ្យសិក្ខាកាមអានករណីសិក្សាខ្លីៗពីរ បន្ទាប់មកទៀតសុំឱ្យពួកគាត់ឆ្លើយសំណួរខាងក្រោម:
- *តើសួនកុមារបែបណាដែលមានលក្ខណៈសមស្របសម្រាប់សិស្សទាំងអស់គ្នា ជាពិសេសកុមារពិការ? សូមពន្យល់ ។*
- *តើសួនកុមារនោះមានលក្ខណៈសមស្របសម្រាប់សិស្សទាំងអស់គ្នា និងកុមារពិការឬទេ បើយោងតាមលទ្ធផលឧបករណ៍ដែលមាននៅក្នុងសួនកុមារនោះ?*
- *នៅពេលបង្កើតសួនកុមារដែលផ្អែកលើមូលដ្ឋានតំរូវការនៃសិស្សពិការ និងសិស្សប្រឈមមុខផ្សេងទៀត តើអ្នកឃើញមានបញ្ហាអ្វីដែលសំខាន់ជាងគេ?*

- ជាដំបូងសិក្ខាកាមត្រូវអាន និងកត់ត្រាចំលើយរបស់ពួកគាត់ជាលក្ខណៈបុគ្គល ហើយបន្ទាប់មកត្រូវធ្វើការជាគូ ហើយគិតអំពីចំលើយរបស់ដៃគូដើម្បីកំណត់គំនិតដូចគ្នា និងខុសគ្នា ។ បន្ទាប់មក អ្នកសម្របសម្រួលសំយោគចំលើយដោយពិភាក្សាទាំងអស់គ្នា ។

### ២. ការវាយតំលៃលើភាពសមស្របដែលមានកល្ខណៈសម្រាប់ទាំងអស់គ្នានៃសួនកុមារ

- ដោយយោងតាមការពិភាក្សាលើបញ្ហាដែលកើតចេញពីករណីសិក្សា អ្នកសម្របសម្រួលសុំឱ្យសិក្ខាកាមកំណត់កត្តាមួយចំនួនដែលអាចកំណត់ថាតើសួនកុមារមានលក្ខណៈសមស្របទៅនឹងកុមារពិការ និងកុមារដែលប្រឈមមុខដែរឬទេ ។
- អ្នកសម្របសម្រួល ត្រូវកត់ចំណាំគំនិតរបស់សិក្ខាកាមដោយសរសេរដាក់នៅលើក្តារខៀន ហើយបង្ហាញគំនិតខ្លះដូចខាងក្រោម:
  - ភាពសហការរបស់កុមារ

- ឱកាសបង្កើនការរៀនរបស់កុមារ
- ការលើស្ទួយសុវត្ថិភាព
- ការថែរក្សាសម្ភារ
- ចំនួនកុមារដែលអាចលេងនៅសួនកុមារ
- ទំនាក់ទំនងរវាងកុមារ និងអ្នកគ្រប់គ្រងសួនកុមារ

- អ្នកសម្របសម្រួលចែកឧបសម្ព័ន្ធ ' ខ ' ដល់សិក្ខាកាម ហើយពន្យល់ថាពួកគាត់ត្រូវវាយតំលៃទៅលើកត្តានិមួយៗ ដូចដែលវាមានទំនាក់ទំនងទៅនឹងស្ថានភាពនៅក្នុងសាលារៀនរបស់ពួកគេដើម្បីវាយតំលៃភាពស្មើភាពសម្រាប់ទាំងអស់គ្នា និងភាពកុមារមេត្រីនៃសួនកុមារ ។ ប្រសិនបើសិក្ខាកាមកំណត់កត្តាបន្ថែមរួចហើយ កត្តាទាំងនេះអាចត្រូវបានគេដាក់បន្ថែមទៅក្នុងទម្រង់វាយតំលៃ (**ឧបសម្ព័ន្ធ ' ខ '**) ។ សូមពន្យល់ថា កូឡោនដែលនៅខាងស្តាំ និងខាងឆ្វេងមានការពិណនាសង្ខេបស្តីអំពីស្ថានភាពនៃភាពកុមារមេត្រីដែលមានលក្ខណៈសមស្របសម្រាប់ទាំងអស់គ្នា និងភាពមិនមែនជាកុមារមេត្រីដែលពាក់ព័ន្ធទៅនឹងកត្តានីមួយៗ ។ អ្នកសម្រសម្រួល សុំឱ្យសិក្ខាកាមដាក់បញ្ចូលការពិណនាដែលដូចគ្នាសម្រាប់កត្តាបន្ថែមដែលពួកគាត់អាចកំណត់បាន ។ លំហាត់វាយតំលៃអាចត្រូវបានធ្វើឡើងជាគូ ឬជាក្រុមតូច អាស្រ័យលើចំនួនសរុបនៃបុគ្គលិក ។

## ៣. ការកំណត់វិធានការដើម្បីកែលំអលើភាពសមស្របដែលមានកលក្ខណៈសម្រាប់ទាំងអស់គ្នានៃសួនកុមារ

- ដោយយោងតាមលំហាត់វាយតំលៃ សិក្ខាកាមត្រូវកំណត់លក្ខណៈដែលសាលារៀនបានផ្តល់ពិន្ទុខ្ពស់ ហើយនិងចំណុចដែលសិក្ខាកាមបានផ្តល់ពិន្ទុទាប ។ មូលហេតុដែលមានពិន្ទុទាបគួរពិភាក្សា ហើយវិធានការគួរត្រូវកំណត់ដើម្បីធ្វើការកែលំអ ។
- វាមានប្រយោជន៍ណាស់ ប្រសិនបើអ្នកសម្របសម្រួលសង្កត់ធ្ងន់ទៅលើភាពលំបាករបស់សិស្សពិការ ដោយប្រើសំណួរ (សំណួរអាចត្រូវបានកែសម្រួលឱ្យសមស្របទៅតាមតំរូវការរបស់កុមារដែលប្រឈមមុខនឹងបញ្ហាជាជាងកុមារពិការ)
    - *តើអ្នកអាចជួយកុមារពិការដើម្បីកុំឱ្យពួកគេមានអារម្មណ៏ថាពួកគេមិនអាចមកលេងក្នុងសួនកុមារបាន?*
    - *តើអ្នកអាចជួយកុមារពិការដើម្បីកុំឱ្យពួកគេមានអារម្មណ៏តូចចិត្ត នៅពេលដែលពួកគេមិនអាចប្រើប្រាស់ឧបករណ៏មួយចំនួន?*
    - *តើអ្នកអាចបង្កើននូវកាយសម្ព័ន្ធរវាងអាវ:យ:វ:ពិការ និងអាវ:យ:វ:មិនពិការនៅពេលពួកគេលេង?*

## ឧបសម្ព័ន្ធ ក : ករណីសិក្សាស្តីអំពីសួនកុមារពីរដែលមានលក្ខណៈខុសគ្នា

### សួនកុមារទី ១

នៅក្នុងសាលាភូមិថ្មី មានសួនកុមារមួយទើបតែត្រូវបានគេកសាងឡើង ដែលមានទោង ៥, ទររំអិល១, ក្តារជិះបះចុះឡើងសម្រាប់ក្មេងលេង និងរបាតោងមួយចំនួន ។ កុមារទាំងអស់គ្នាមានអារម្មណ៍រំភើបអំពីសួនកុមារ ហើយតែងតែទន្ទឹងរង់ចាំលេង ។ ព្រមជាមួយនេះដែរ គ្រូក៏ពេញចិត្តដែរ ពីព្រោះវាបានកែលំអលក្ខណៈរបស់សួនកុមាររបស់សាលារៀន ។ គ្រូមួយចំនួនអះអាងថា ជាដំបូងវាបានកែលំអយ៉ាងទៀងទាត់លើវត្តមានរបស់កុមារ ដែលបានមករៀនមុនម៉ោង ៧ ដើម្បីឱ្យពួកគេអាចលេងនៅក្នុងសួនកុមារបាន ។ ពេលចេញលេង សិស្សទាំងអស់ចេញមកខាងក្រៅទៅលេងនៅក្នុងសួនកុមារ ហើយពួកគេសង្ឃឹមថានឹងបានលេងទោង ឬសម្ភារណាមួយ ។ នៅពេលដែលកំពុងរត់យ៉ាងលឿន កុមារតូចៗជាញឹកញាប់ដួលនៅពេលលេង ឬនៅរង់ចាំរហូតសិស្សធំៗលេងចប់ ។ សុខាដែលរៀននៅថ្នាក់ទី ៥ ដែលប្រើឈើច្រាត់ អង្គុយមើលមិត្តរួមថ្នាក់របស់នាងលេងក្នុងសួនកុមារ ។

### សួនកុមារទី ២

ប៉ុន្មានឆ្នាំក្រោយមក សាលាភូមិចាស់បានរៀបចំសួមកុមារមួយដោយថវិកាបានមកពីការរៃអង្គាសពីសហគមន៍ ដែលមានទោង ២, ទររំអិល ១ និងក្តារជិះបះចុះឡើងសម្រាប់ក្មេងលេង ១ ។ ទីធ្លានៅជុំវិញសួនកុមារហាប់ល្អ ប៉ុន្តែប្រជាជនចេះតែមកជីក និងបោះ/ខ្ចាតដីខ្សាច់លើសម្ភារលេងរបស់ក្មេងជាប្រចាំ ។ ថ្ងៃនេះ តារា ដែលជាក្មេងតូចម្នាក់ ហើយអៀនរៀននៅថ្នាក់ទី១ ត្រូវមកលេងនៅក្នុងសួនកុមារ ព្រោះនេះជាវេណរបស់ថ្នាក់គេ ។ តារាងអៀនដោយសារតែគេនែបបបូរមាត់ ។ ជួនកាលក្មេងដ៏ទៃសើចចំអកឱ្យតារា ប៉ុន្តែគេពិតជារីករាយនឹងការលេងនៅក្នុងសួនកុមារណាស់ ។ សិស្សក្នុងថ្នាក់របស់តារាត្រូវបានគេឱ្យលេងជាគូនឹងសិស្សថ្នាក់ទី ៦ ដើម្បីជួយ។ សម្ភារនីមួយៗត្រូវបានគ្រប់គ្រងដោយសិស្ស ២នាក់មកពីថ្នាក់ទី ៦ ហើយសិស្សទាំងនេះត្រូវធានាឱ្យបានថាគ្រប់គ្នាបានលេងម្នាក់ម្តងៗ ។ តារាសប្បាយរីករាយខ្លាំងណាស់នឹងការលេងទររំអិល ពីព្រោះសុវណ្ណដែលមកពីថ្នាក់ទី ៦ ត្រូវបានតែងតាំងឱ្យធ្វើជាអ្នកជួយ ។ សុវណ្ណកំណត់បានថាកុមារទាំងអស់ត្រូវលេងជិះទររំអិលម្តងម្នាក់ៗ ដោយមិនរុញគ្នា ។ មុនពេលដែលសុវណ្ណក្លាយជាអ្នកជួយ តារាខ្លាចមិនហានជិះទររំអិលទេ ព្រោះមិត្តរបស់គេចេះតែរុញគេចុះក្រោមខ្លាំងពេក ទាំងខ្លួនមិនទាន់ត្រៀមខ្លួនរួចផង ។ មិត្តរបស់តារាឈ្មោះសម្បត្តិក៏រីករាយនឹងការលេងក្នុងសួនកុមារដែរ ព្រោះមានអ្នកនៅរង់ចាំជួយ ។ សម្បត្តិប្រើរទេះកង់រុញ ហើយភាព និងសុម៉ានីដែលមកពីថ្នាក់ទី ៥ មកលើកតារាចេញពីរទេះដាក់លើទោងកង់ឡាន ។ ពួកគេជួយរុញតារាទៅវិញទៅមក ហើយដោយសារ ពួកគេទាំងពីរនាក់ឈរនៅទីនោះ ធ្វើឱ្យតារាមិនខ្លាចអ្វីទាំងអស់ ។ មានពេលខ្លះ ភាព និងសុម៉ានីនៅចាំតារារហូតទាល់តែគេចេញទៅផ្ទះអស់ ហើយនៅជួយតារាលេងទោងទៀត ។

## ឧបសម្ព័ន្ធ ២ : ការវាយតំលៃលើភាពសមស្របដែលមានលក្ខណៈសម្រាប់ទាំងអស់គ្នានៃសួនកុមារ

| លក្ខណៈមិនសម្រាប់ទាំងអស់គ្នា | កត្តាទំនាក់ទំនងនឹងមេត្រីភាពនៃសួនកុមារ | លក្ខណៈមេត្រីភាព និងសម្រាប់ទាំងអស់គ្នា |
|---|---|---|
| សិស្សស្រី លេងជាមួយសិស្សស្រី ហើយសិស្សប្រុសលេងជាមួយសិស្សប្រុស ។ សិស្សក្រីក្រ, សិស្សពិការ និងសិស្សតូចៗហាក់ដូចជាត្រូវបានគេដកចេញពីការលេងនៅក្នុងសួនកុមារ ។ | សូមវាយតំលៃ "**<u>កិច្ចសហការគ្នារវាងកុមារ</u>** " ក្នុងពេលលេងក្នុងសួនកុមារ ពីទាប (១) ទៅខ្ពស់ (១០) ។<br>១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ | ទាំងសិស្សប្រុស និងសិស្សស្រីលេងក្នុងសួនកុមារជាមួយគ្នា ហើយសិស្សធំៗជួយសិស្សតូចៗ និងសិស្សពិការ ។ |
| ទង់ជាតិ, ព្យញ្ជនៈ, ឈ្មោះរុក្ខជាតិ និងព័ត៌មានផ្សេងទៀតត្រូវបានគេដាក់ព្យួរនៅក្នុងសួនកុមារ ប៉ុន្តែទំហំអក្សរតូចបណ្តាលឱ្យកុមារតូចៗ និងកុមារអន់ភ្នែកពិបាកអាន ។ | សូមវាយតំលៃ "**<u>ឱកាសពង្រឹងការរៀន</u>** " ក្នុងពេលលេងក្នុងសួនកុមារ ពីទាប (១) ទៅខ្ពស់ (១០) ។<br>១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ | ទង់ជាតិ, ព្យញ្ជនៈ, ឈ្មោះរុក្ខជាតិ និងព័ត៌មានផ្សេងទៀតត្រូវបានគេដាក់បង្ហាញនៅក្នុងសួនកុមារយ៉ាងច្បាស់សម្រាប់មើល ។ កុមារត្រូវបានគេមើលឃើញថាចេះជួយគ្នាទៅវិញទៅមក ។ |
| នៅក្នុងទីធ្លាសួនមានថ្ម ហើយឧបករណ៍ផ្សេងៗត្រូវបានដាក់នៅកៀកគ្នាពេកថែមទាំងគ្មានការត្រួតពិនិត្យទៀត ។ | សូមវាយតំលៃ "**<u>ការបង្កើនសុវត្ថិភាព</u>** " ក្នុងពេលលេងក្នុងសួនកុមារពីទាប (១) ទៅខ្ពស់ (១០) ។<br>១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ | ក្នុងមានទីធ្លាគ្រប់គ្រាន់ និងមានដីខ្សាច់នៅចន្លោះឧបករណ៍លេងនីមួយៗ ព្រមទាំងមានការត្រួតពិនិត្យត្រឹមត្រូវ ។ |
| សម្ភារមានសុទ្ធតែច្រេះ ហើយទោងខ្ពស់ពេកសម្រាប់កុមារតូចៗ ។ គ្មាននរណានៅចាំជួយកុមារដែលពិការឱ្យលេងសម្ភារទាំងនេះទេ ។ | សូមវាយតំលៃ "**<u>ការថែរក្សាឧបករណ៍</u>** " ក្នុងពេលលេងក្នុងសួនកុមារពីទាប(១) ទៅខ្ពស់ (១០) ។<br>១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ | មានការសំអាតតាមកាលវិភាគទប់ទល់នឹងហេតុផ្សេងៗ ដូចជាកំទេចច្រេះដែក, ខ្សែរពុកផុយ ជាដើម ។ កន្លែងលើទោងមានកម្ពស់សមរម្យទៅកុមារតូច-ធំ ។ |

| | | |
|---|---|---|
| សម្ភារអាចលេងបានសម្រាប់តែសិស្សធំៗ និងសិស្សដែលមិនពិការ ។ | សូមវាយតំលៃ "**<u>អាយុសិស្សដែលលេងក្នុងសួនកុមារ</u>**" ក្នុងពេលលេងក្នុងសួនកុមារពីទាប(១)ទៅខ្ពស់(១០) ។<br>១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ | កុមារទាំងអស់មានឱកាសលេងឧបករណ៍ រួមទាំងសិស្សពិការផងដែរ ។ |
| គ្មានគ្រូនៅទីនោះ ឬគ្រូ និងសិស្សធំៗនៅទីនោះគ្រាន់តែចាំមើលថែរក្សាវិន័យប៉ុណ្ណោះ ។ | សូមវាយតំលៃ "**<u>ទំនាក់ទំនងរវាងកុមារ និងអ្នកគ្រប់គ្រងសួនកុមារ</u>**" ក្នុងពេលលេងក្នុងសួនកុមារពីទាប(១)ទៅខ្ពស់(១០) ។<br>១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ | គ្រូ និងសិស្សធំៗស្គាល់ឈ្មោះកុមារតូចៗទាំងអស់ ព្រមទាំងខិតខំរិះរកមធ្យោបាយដើម្បីជំរុញឱ្យសិស្សពិការបានចូលរួមលេងឧបករណ៍នៅក្នុងសួនកុមារ ។ |
| (ចូរពណ៌នាអំពីលក្ខណៈមិនសម្រាប់ទាំងអស់គ្នាដោយផ្អែកលើកត្តាដែលផ្តល់ឱ្យដោយសិក្ខាកាម) | សូមវាយតំលៃ "<u>............................................</u>" ក្នុងពេលលេងក្នុងសួនកុមារពីទាប(១)ទៅខ្ពស់ (១០) (*ចូរបន្ថែមកត្តាផ្សេងៗដែលបានមកពីសិក្ខាកាម*)។<br>១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ | (ចូរពណ៌នាអំពីលក្ខណៈមេត្រីភាព និងសម្រាប់ទាំងអស់គ្នាដោយ ផ្អែកលើកត្តាដែលផ្តល់ឱ្យដោយសិក្ខាកាម) |